# ការបង្ការ និងការឆ្លើយតបចំពោះការបោះបង់កុមារចោលនៅមន្ទីរពេទ្យ

## សេចក្តីសង្ខេបអំពីវីដេអូ

មន្ទីរពេទ្យ និងមណ្ឌលសុខភាព គឺជាទីតាំងគន្លឹះដែលមានករណីការបោះបង់កុមារចោលច្រើន ជាពិសេសចំពោះកុមារកើតមកមានពិការភាព មានជំងឺពីកំណើត ឬក្នុងករណីមានផ្ទៃពោះមិនបានគ្រោងទុក។ ជារឿយៗ បញ្ហាបោះបង់កុមារ កើតមានដោយមានកត្តាជាសម្ពាធជាច្រើនដែលគ្រួសារត្រូវជួបប្រទះបូករួមជាមួយភាពរន្ធត់ និងកង្វះព័ត៌មានស្តីពីពិការភាព ឬជំងឺពីកំណើត និង/ឬការមាក់ងាយ ដែលជាលទ្ធផលធ្វើឱ្យគ្រួសារមានអារម្មណ៍ថា មិនអាចទទួលយកបាន និងមិនអាចផ្តល់ការថែទាំដល់កុមារបាន។

ក្នុងវីដេអូដែលចែកជាពីរផ្នែកនេះ លោក សន សុខជា ធ្វើការពិភាក្សាអំពីកម្មវិធីសង្គមកិច្ចក្នុងវិស័យវេជ្ជសាស្ត្រ ដំណើរការដោយមន្ទីរពេទ្យកុមារអង្គរក្នុងប្រទេសកម្ពុជា ដែលមានបំណងបង្ការ និងឆ្លើយតបចំពោះការបោះបង់ចោលកុមារ ក្នុងគោលដៅដើម្បីពង្រឹងគ្រួសារឱ្យអាចផ្តល់ការថែទាំគ្រប់គ្រាន់សម្រាប់កុមារ។

ក្នុងផ្នែកទីមួយ លោក សុខជា ចែករំលែកទស្សនៈមួយចំនួន ផ្អែកលើមេរៀនទទួលបានសំខាន់ៗរបស់នាយកដ្ឋានសង្គមកិច្ច ជុំវិញមូលហេតុដែលនាំឱ្យមានការបោះបង់កុមារ របៀបដើម្បីធ្វើការជាមួយគ្រួសារក្នុងការ កំណត់បញ្ហា និងដោះស្រាយបញ្ហាឫសគល់ របៀបដើម្បីបង្កការចូលរួម និងប្រាស្រ័យទាក់ទងជាមួយគ្រួសារ និងរបៀបដើម្បីកំណត់រកសូចនាករហានិភ័យដែលអាចនាំទៅដល់ការបោះបង់កុមារចោល។

ក្នុងផ្នែកទីពីរ លោក សុខជា ចែករំលែកទស្សនៈមួយចំនួនស្តីពីរបៀបតាមដានរកគ្រួសារ សម្រាប់ករណីដែលកុមារត្រូវបានបោះបង់ចោលរួចហើយ និងវិធីដើម្បីកំណត់រកប្រភពព័ត៌មានជាតម្រុយ និងប្រភពព័ត៌មានគន្លឹះសំខាន់ៗ។

## ប្រធានបទពិភាក្សា៖

### និយាមនិងជំនឿតាមបែបវប្បធម៌

ក្នុងវីដេអូនេះ លោក សុខជា បានផ្សារភ្ជាប់បញ្ហាការបោះបង់កុមារចោលជាមួយនិយាម និងជំនឿតាមបែបវប្បធម៌ ទាំងទាក់ទងជាមួយការយល់ដឹងអំពីបុព្វហេតុនៃការបោះបង់កូន និងវិធីប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កឱ្យមានការចូលរួម និងការប្រាស្រ័យទាក់ទងជាមួយគ្រួសារ ដើម្បីគាំទ្រដល់ការបង្រួបបង្រួមកុមារជាមួយគ្រួសារវិញ។ លោកទទួលស្គាល់អំពីភាពចាំបាច់នៃចំណុចនេះចំពោះជោគជ័យ ដោយហេតុថា ឥរិយាបថ និងអាកប្បកិរិយារបស់ឪពុកម្តាយឆ្លើយតបចំពោះស្ថានភាពរបស់ខ្លួន គឺរងឥទ្ធិពលយ៉ាងខ្លាំងពីជំនឿ និងនិយាមបែបវប្បធម៌។ ទាក់ទងជាមួយចំណុចនេះ លោក សុខជា លើកឡើងអំពីភាពចាំបាច់ឱ្យអ្នកសង្គមកិច្ច ត្រូវប្រាស្រ័យទាក់ទងជាមួយគ្រួសារ ធ្វើយ៉ាងណាដើម្បីបំបាត់ឧបសគ្គផ្នែកវប្បធម៌ និងផ្នែកសង្គមជាសក្តានុពលនានា ដូចជាឋានានុក្រមការមាក់ងាយ និងការរើសអើង ដើម្បីឱ្យពួកគេអាចពង្រឹងឱ្យមានទំនាក់ទំនងដោយបើកចំហ និងទុកចិត្តគ្នាជាមួយគ្រួសារ។ ក្នុងបរិបទនេះ លោក សុខជា និយាយថា ក្នុងការងារនេះយើងត្រូវ “ធ្វើការជាមួយគ្រួសារ ប្រៀបដូចជាយើងជាសមាជិកក្នុងគ្រួសារនោះដែរ”។

### ក្នុងបរិបទរបស់អ្នក៖

- តើទំនាក់ទំនងល្អរវាងអ្នកសង្គមកិច្ច ជាមួយអតិថិជនត្រូវមានលក្ខណៈបែបណាខ្លះ ហើយតើអ្នកសង្គមកិច្ចចាំបាច់ត្រូវមានទំនាក់ទំនងជាមួយអតិថិជនរបស់ខ្លួនដោយរបៀបណា ដើម្បីជំរុញឱ្យមានទំនាក់ទំនងដ៏រឹងមាំ? តើមានឧបសគ្គផ្នែកវប្បធម៌ និងផ្នែកសង្គមណាមួយ (ដូចជាការខ្លាចបាក់មុខ ឬការមិនទុកចិត្តលើអ្នកប្រកបវិជ្ជាជីវៈ) ដែលគោលវិធីនេះជួយជម្នះ ឬទេ?
- តើជំនឿ និងនិយាមវប្បធម៌អ្វីខ្លះ ដែលប៉ះពាល់ចំពោះបញ្ហាដែលអង្គការរបស់អ្នកកំពុងព្យាយាមដោះស្រាយ?
- តើកម្មវិធី ឬយុទ្ធនាការរបស់អ្នក ព្យាយាមឆ្លើយតបជាមួយជំនឿ និងនិយាមវប្បធម៌ទាំងអស់នេះ តាមវិធីណាខ្លះ ដើម្បីជះឥទ្ធិពលឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាក្នុងការឆ្លើយតប ឬអន្តរាគមន៍របស់អ្នក?
- តើអង្គការរបស់អ្នកអាចប្រើប្រាស់និយាមផ្នែកវប្បធម៌ និងគុណតម្លៃណាខ្លះ ដើម្បីលើកកម្ពស់ការចិញ្ចឹមបីបាច់កូនជាវិជ្ជមាន អាកប្បកិរិយាជាវិជ្ជមាន ឬការអនុវត្តដែលមានលក្ខណៈគួរជាទីចង់បាន?

ប្រធានបទពិភាក្សា៖

## ការតាមរកគ្រួសារ

ក្នុងផ្នែកទីពីរនៃវីដេអូនេះ លោក សុខជា ពន្យល់អំពីជំហាន និងទំហំការងារដែលអ្នកសង្គមកិច្ច ចាំបាច់ត្រូវធ្វើដើម្បីតាមរកគ្រួសារ និងធានាឱ្យបានថាកុមារត្រូវបានបញ្ជូនទៅទទួលការថែទាំជំនួសរយៈពេលវែងតែក្នុងករណីដែលចាំបាច់ខានមិនបានប៉ុណ្ណោះ។ លោកបញ្ជាក់ថា ជោគជ័យភាគច្រើនគឺបានមកពីការប្តេជ្ញាចិត្ត និងជំនឿជឿជាក់របស់អ្នកសង្គមកិច្ច ដោយហេតុថា ជាទូទៅតែងតែមានតម្រុយដែលអាចរកឃើញ និងអាចតាមដានរកបន្តទៀតបាន។ ថ្វីបើនេះជាការពិតមែនក្តី ប៉ុន្តែការតាមដានរកតម្រុយទាំងនោះ គឺត្រូវអាស្រ័យលើបរិស្ថានអំណោយផលដែលមានក្នុងអង្គភាព និងអាទិភាពដែលត្រូវបានផ្តោតលើការវិនិយោគក្នុងការតាមរកគ្រួសារ និងការបង្រួបបង្រួមកុមារជាមួយគ្រួសារវិញ។ ក្នុងករណីរបស់មន្ទីរពេទ្យកុមារអង្គរ ការងារនេះ គឺតម្រូវឱ្យមាននាយកដ្ឋានសង្គមកិច្ចនៅក្នុងមន្ទីរពេទ្យ និងផ្តល់ធនធានដល់បុគ្គលិក ដើម្បីធ្វើការតាមរកគ្រួសារនៅក្នុងមន្ទីរពេទ្យ និងក្នុងសហគមន៍ ក៏ដូចជាអនុវត្តផែនការពង្រឹងគ្រួសារផងដែរ។

## ក្នុងបរិបទរបស់អ្នក៖

? តើមានកត្តាអំណោយផលអ្វីខ្លះក្នុងអង្គភាពរបស់អ្នក ដែលគាំទ្របុគ្គលិក និងអ្នកសង្គមកិច្ច ឱ្យអាចវិនិយោគលើការតាមរកគ្រួសារ ការពង្រឹងគ្រួសារ និងការបង្រួបបង្រួមកុមារជាមួយគ្រួសារវិញ ដើម្បីធានាឱ្យបានថាមានកិច្ចខិតខំតាមគ្រប់មធ្យោបាយដើម្បីបង្រួបបង្រួមកុមារជាមួយគ្រួសារកំណើត ឬរក្សាកុមារជាមួយគ្រួសារកំណើតរបស់ខ្លួន?

? តើឧបសគ្គរារាំង (ផ្នែករចនាសម្ព័ន្ធ ធនធាន កម្មវិធី ចំណេះដឹងបច្ចេកទេស) អ្វីខ្លះ ដែលដាក់ដែនកំណត់លើសមត្ថភាពរបស់បុគ្គលិក ក្នុងការវិនិយោគឱ្យបានច្រើនលើការងារថែរក្សាគ្រួសារ និងការបង្រួបបង្រួមគ្រួសារ?

? តើចាំបាច់ត្រូវផ្លាស់ប្តូរ អភិវឌ្ឍ ឬពង្រីកអ្វីខ្លះ ដើម្បីធានាឱ្យបានថាការថែទាំជំនួសត្រូវបានយកមកប្រើប្រាស់តែនៅពេលចាំបាច់ និងជាឧត្តមប្រយោជន៍របស់កុមារប៉ុណ្ណោះ ហើយការបំបែកកុមារចេញពីគ្រួសារ គឺសម្រាប់រយៈពេលខ្លីបំផុតតាមដែលអាចធ្វើបាន?

## ករណីសិក្សា

ឪពុក៖ ខ្ញុំរំភើបណាស់ ពេលខ្ញុំដឹងថាប្រពន្ធរបស់ខ្ញុំមានផ្ទៃពោះ។ ពេលគភ៌បានប្រាំខែ យើងបានទៅផ្ទះអេកូ ហើយវេជ្ជបណ្ឌិតបានប្រាប់ថាកូនរបស់យើងមានសុខភាពល្អ អ្វីៗមើលទៅហាក់ដូចប្រក្រតី។ ដល់ពេលប្រពន្ធរបស់ខ្ញុំទៅឆ្លងទន្លេ ពេលនោះខ្ញុំនៅកន្លែងធ្វើការ។ ខ្ញុំបានទទួលទូរសព្ទពីម្តាយក្មេករបស់ខ្ញុំប្រាប់ថា កូនស្រីរបស់ខ្ញុំកើតហើយ ប៉ុន្តែនាងឆែបមាត់។ ខ្ញុំមានអារម្មណ៍តានតឹងភ្លាមៗ និងមិនអាចទទួលយកបាន។ ខ្ញុំទៅមន្ទីរពេទ្យភ្លាម ហើយបាននិយាយជាមួយប្រពន្ធខ្ញុំ។ ខ្ញុំបាននិយាយថា ខ្ញុំមិនដឹងថាតើ យើងនឹងថែទាំទារកនេះ និងរក្សានាងឱ្យមានជីវិតដោយរបៀបណាទេ។

ម្តាយ៖ ខ្ញុំសែនសប្បាយចិត្តជាខ្លាំង ពេលខ្ញុំដឹងថា ខ្ញុំនឹងមានកូន ប៉ុន្តែពេលកូនរបស់ខ្ញុំកើតមកមានឆែបមាត់ ខ្ញុំហាក់បាត់បង់អ្វីៗទាំងអស់។ ខ្ញុំរន្ធត់ជាខ្លាំង ខ្ញុំពុំអាចនិយាយរកនរណាចេញទេ ខ្ញុំមិនដឹងជាត្រូវថែទាំកូននេះយ៉ាងដូចម្តេច ហើយខ្ញុំបារម្ភក្រែងតែនាងមិន រស់។ ខ្ញុំបានព្យាយាមបញ្ចុកនាងរយៈពេលប៉ុន្មានថ្ងៃដំបូង ប៉ុន្តែទឹកដោះហូរចេញពីមាត់របស់នាង ហើយនាងចេះតែឈ្លក់ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចទទួលយកបានទេ។ អ្នកជិតខាងម្នាក់បានប្រាប់ខ្ញុំថា មន្ទីរពេទ្យកុមារអង្គរអាចវះកាត់កុមារដែលមានមាត់ឆែប ហើយដល់ពេលនោះនឹងលែងអីហើយ ប៉ុន្តែខ្ញុំមិនសូវជឿគេនោះទេ។ ពួកយើងបាននាំកូនមកមន្ទីរពេទ្យកុមារអង្គរ គេនិយាយថា គេអាចវះកាត់បានពេលកូនអាយុ ៧ ខែ ហើយគេថាច្បាស់ជាគ្មានបញ្ហាទេ។ ពួកយើងគិតថា គេគ្រាន់តែនិយាយដើម្បីលួងលោមយើងប៉ុណ្ណោះ ហើយពួកយើងមិនជឿគេទេ។ យើងបានសម្រេចចិត្តថាជាការល្អគួរតែទុកកូនរបស់យើងនៅមន្ទីរពេទ្យ។

ឪពុក៖ បន្ទាប់មក អ្នកសង្គមកិច្ចម្នាក់នៅមន្ទីរពេទ្យកុមារអង្គរបានទំនាក់ទំនងមកពួកយើង។ គេបានចាប់ផ្តើមប្រឹក្សាយោបល់ជាមួយយើង ជួយយើងឱ្យយល់អំពីបញ្ហា និងធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហានោះ ដោយបានពន្យល់អំពីការគាំទ្រដែលពួកគេអាចផ្តល់ឱ្យ និងបានជួយយើងឱ្យអាចជម្នះលើអារម្មណ៍ច្របូកច្របល់ និងក្តីរន្ធត់នៅក្នុងចិត្តរបស់ពួកយើង។ ពួកគេបានប្រាប់យើងឱ្យត្រលប់ទៅមើលកូនរបស់យើងនៅមន្ទីរពេទ្យ ហើយពួកគេចេញថ្លៃសម្រាប់ការធ្វើដំណើរឱ្យយើង។

ម្តាយ៖ ពេលយើងទៅដល់មន្ទីរពេទ្យ អ្នកសង្គមកិច្ចបានចំណាយពេលជាច្រើននៅជាមួយយើង។ គេបានពន្យល់អំពីកាគាំទ្រទាំងអស់ដែលគេអាចផ្តល់ឱ្យយើងបាន រួមទាំងការវះកាត់ និងថ្លៃធ្វើដំណើរសម្រាប់ឱ្យកូនរបស់យើងណាត់ជួបជាមួយពេទ្យ ព្រមទាំងការគាំទ្រក្នុងការប្រឹក្សាយោបល់សម្រាប់ពួកយើង។ គេបានបង្ហាញរូបថតកុមារដទៃទៀតដើម្បីឱ្យយើងមើលឃើញថា បញ្ហានេះមិនធ្ងន់ធ្ងរដូចពួកយើងគិតទេ។ ពួកគេបានផ្តល់ដំបូន្មាន និងឆ្លើយគ្រប់សំណួររបស់យើងទាំងអស់។ ពួកគេបានផ្តល់ដបពិសេសដើម្បីបញ្ចុកកូនរបស់យើង និងបានពន្យល់អំពីរបៀបប្រើដបនោះ។ យើង

នៅតែមិនស្លូវទាន់ប្រាកដក្នុងចិត្ត ប៉ុន្តែពួកយើងបានសម្រេចចិត្តយកកូនមកផ្ទះវិញ។ ពួកគេបានលើកទឹកចិត្តយើង និងធ្វើឱ្យយើងជឿថា យើងអាចធ្វើបាន។

ឪពុក៖ ដល់គ្រប់ ៧ ខែ យើងនាំកូនរបស់យើងត្រលប់ទៅទទួលការវះកាត់លើកទីមួយក្នុងចំណោមការវះកាត់ទាំងបីលើក។ អ្នកសង្គមកិច្ច និងវេជ្ជបណ្ឌិតបានពន្យល់ប្រាប់យើងយ៉ាងលម្អិត អំពីអ្វីដែលនឹងកើតមាន ហើយអ្វីដែលយើងអាចរំពឹងថានឹងមើលឃើញ។ ការវះកាត់នោះ បានផលល្អណាស់ យើងអាចមើលឃើញថា កូនរបស់យើងមានសភាពខុសប្លែកពីមុនច្រើន។

ដល់ពេលនេះ ទើបយើងមើលឃើញថា យើងអាចជឿអ្នកសង្គមកិច្ចបានទាំងស្រុង ព្រោះគ្រប់យ៉ាងដែលគេប្រាប់យើង គឺជាការពិតមែន។ អ្វីដែលពួកគាត់ប្រាប់ គឺពុំមែនគ្រាន់តែជាការនិយាយចោលនោះទេ។

ម្តាយ៖ បន្ទាប់ពីការវះកាត់លើកទីមួយហើយ ខ្ញុំមើលឃើញថា អ្វីៗនឹងបានប្រសើរឡើង ហើយខ្ញុំទុកក្តីបារម្ភទាំងអស់ចោល ហើយជាលើកដំបូងដែលខ្ញុំអាចស្រលាញ់កូនរបស់ខ្ញុំអស់ពីដួងចិត្ត។